ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៣១...អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកែសម្រួលអនុក្រឹត្យលេខ៥៦ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៩៣ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា២ មាត្រា៣ និងមាត្រា៤ នៃអនុក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈ-កម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤ ស្តីពី បង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យហិរញ្ញវត្ថុ

www.pheakdeylaw.com

- បានឃើញ អនុក្រឹត្យលេខ ៥៦ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ
- យោងតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រាមួយ.-

មាត្រា៣ថ្មី មាត្រា៥ និងមាត្រា៧ នៃអនុក្រឹត្យលេខ ៥៦ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ ត្រូវបានធ្វើការកែសម្រួល ដូចខាងក្រោម៖

មាត្រា៣ ថ្មី (មួយ).-

គ.ម.ហ. មានសមាសភាព ដូចខាងក្រោម៖

១.	ទេសាភិបាលធនាគារជាតិនៃកម្ពុជា	ប្រធាន
២.	ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា	អនុប្រធានប្រចាំការ
៣.	រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	អនុប្រធាន
៤.	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៥.	តំណាងក្រសួងមហាផ្ទៃ	សមាជិក
៦.	តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៧.	តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
៨.	តំណាងក្រសួងអភិវឌ្ឍន៍ជនបទ	សមាជិក
៩.	តំណាងក្រសួងឧស្សាហកម្មនិងសិប្បកម្ម	សមាជិក
១០.	តំណាងក្រសួងកិច្ចការនារី	សមាជិក
១១.	តំណាងក្រសួងអប់រំ យុវជន និងកីឡា	សមាជិក
១២.	តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ	សមាជិក
១៣.	អគ្គលេខាធិការ ធនាគារជាតិនៃកម្ពុជា	លេខាធិការ
១៤.	អគ្គនាយក នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	សមាជិក
១៥.	តំណាងធនាគារអភិវឌ្ឍន៍ជនបទ	សមាជិក
១៦.	តំណាងសមាគមធនាគារនៅកម្ពុជា	សមាជិក
១៧.	តំណាងសមាគមស្ថាប័នមីក្រូហិរញ្ញវត្ថុកម្ពុជា	សមាជិក
១៨.	តំណាងសហគមន៍អភិវឌ្ឍន៍កសិកម្ម	សមាជិក

សមាសភាពជាក់ស្តែងនៃ **គ.ហ.ម.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

មាត្រា៥ ថ្មី.-

គ.ម.ហ មានរបបប្រជុំសាមញ្ញ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ព្រមទាំងអាចប្រជុំជាវិសាមញ្ញ តាមការចាំបាច់។

សមាសភាពនៃ **គ.ម.ហ** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានត្រូវកោះអញ្ជើញ និងដឹកនាំប្រជុំ **គ.ម.ហ** តាមការប្រគល់សិទ្ធិរបស់ប្រធាន។

គ.ម.ហ មានសិទ្ធិប្រើប្រាស់ត្រារបស់ធនាគារជាតិនៃកម្ពុជាសម្រាប់ដំណើរការការងាររបស់ខ្លួន។

www.pheakdeylaw.com

មាត្រា៧ ថ្មី.-

គ.ម.ហ មានលេខាធិការដ្ឋានមួយនៅធនាគារជាតិនៃកម្ពុជា ជាសេនាធិការ ក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន។

ការរៀបចំ និងការប្រព្រឹត្តិទៅនៃលេខាធិការដ្ឋាន **គ.ម.ហ** ត្រូវបានកំណត់ដោយប្រកាសរបស់ទេសាភិបាលធនាគារជាតិនៃកម្ពុជា ដែលជាប្រធាន **គ.ម.ហ** ។

មាត្រាពីរ.-

អនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៥ ស្តីពី ការកែសម្រួលមាត្រា៣ នៃអនុក្រឹត្យលេខ៥៦ អនក្រ.បក ស្តីពី ការបង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ និងបទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រាបី.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com